ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់ប្រើប្រាស់ដោយចីរភាពលើផ្ទៃដីទំហំ ៤.២៧៣ ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំណាមល្យើរ និងការធ្វើអនុបយោគដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១:** – ធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រង់មាត្រា ១ ត្រូវបានកែសម្រួលពីពាក្យ "ផ្តល់" មកជាពាក្យ "សម្បទាន" វិញ ដែលមានខ្លឹមសារនៃមាត្រា១ ដូចខាងក្រោម:

"ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំណាមល្យើរ លើផ្ទៃដីទំហំ**បួនពាន់ពីររយចិតសិបបី( ៤.២៧៣) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងទីតាំងភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដូចមានក្នុង

ផែនទី និងនិយាមកាជូនភ្ជាប់ជាមួយ សម្រាប់ផ្តល់ជាដី **សម្បទាន** ជូនក្រុមហ៊ុន **សេដ្ឋិកុលា** (SETHIKULA Co., Ltd.) រយៈពេល ៩៩ឆ្នាំ ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ ។"

**មាត្រា២:** -

ខ្លឹមសារនៃមាត្រាផ្សេងទៀតរបស់អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩ នៅមានសុពលភាពដដែល ។

**មាត្រា៣** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៣ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទីទីតាំង ទីតាំងដីរបស់ក្រុមហ៊ុនសិដ្ឋីគុលា(SETHIKULA Co. Ltd) ដែលស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃភ្នំណាមលៀរ ខេត្តមណ្ឌលគីរី ផ្ទៃដីចំនួន ៤,២៧៣ ហិកតារ










| ID | MARK | COOR_X | COOR_Y |
|---|---|---|---|
| 1 | A | 767660 | 1390695 |
| 2 | B | 769607 | 1390780 |
| 3 | C | 769808 | 1388841 |
| 4 | D | 770673 | 1388851 |
| 5 | E | 770663 | 1383997 |
| 6 | F | 770009 | 1384000 |
| 7 | G | 770013 | 1383024 |
| 8 | H | 766505 | 1382993 |
| 9 | I | 766989 | 1380020 |
| 10 | J | 770139 | 1382020 |
| 11 | K | 771899 | 1383905 |
| 12 | L | 773200 | 1386200 |
| 13 | M | 773200 | 1387840 |
| 14 | N | 773200 | 1391591 |
| 15 | O | 771985 | 1391591 |
| 16 | P | 771985 | 1393986 |
| 17 | Q | 767872 | 1393999 |